


## សាវតារ

គំនិតផ្តួចផ្តើមនៃការផ្សព្វផ្សាយព័ត៌មានថវិកាគឺជាកម្មវិធីស្រាវជ្រាវ និងតស៊ូមតិពិភពលោកមួយ ដើម្បីជម្រុញឱ្យមានការទទួលបានជាសាធារណៈនូវព័ត៌មានថវិកា និង ការអនុវត្តប្រព័ន្ធថវិកាដែលមានគណនេយ្យភាពខ្ពស់។ ភាពជាដៃគូថវិកាអន្តរជាតិ (IBP) ដែលមានទីស្នាក់ការនៅទីក្រុងវ៉ាស៊ីនតោនបានបង្កើតគំនិតផ្តួចផ្តើមនេះតាមរយៈ **អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា (OBS)** ដើម្បីវាយតម្លៃលើលទ្ធភាពរកបានឯកសារថវិកាសំខាន់ៗចំនួនប្រាំបី ក៏ដូចជាភាពគ្រប់ជ្រុងជ្រោយនៃទិន្នន័យដែលមាននៅក្នុងឯកសារទាំងនេះ នៅក្នុងប្រទេសនីមួយៗ។ លើសពីនេះទៀត អង្កេតនេះក៏វាយតម្លៃផងដែរនូវវិសាលភាពនៃការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពដែលធ្វើឡើងដោយស្ថាប័ននីតិប្បញ្ញត្តិនិងសវនកម្ម និងវាយតម្លៃមើលថាតើរដ្ឋាភិបាលមានផ្តល់ដល់សាធារណជននូវលទ្ធភាពក្នុងការទទួលបានព័ត៌មានថវិកា និងឱកាសចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តស្តីពីថវិកាជាតិឬទេ។ គេមានជំនឿកាន់តែខ្លាំងឡើងថា ការទទួលបានជាសាធារណៈនូវព័ត៌មានថវិកា តម្លាភាពថវិកា និងការចូលរួមជាសាធារណៈក្នុងដំណើរការថវិកា គឺជាមូលដ្ឋានគ្រឹះនៃរដ្ឋាភិបាលដែលប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព។ បើគ្មានលទ្ធភាពទទួលបានព័ត៌មានថវិកានោះទេ អ្នកតាក់តែងច្បាប់ សវនករ អង្គការសង្គមស៊ីវិល សារព័ត៌មាន និងសាធារណជនទូទៅមិនអាចចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តទេ ហើយពួកគេក៏មិនអាចទាមទារឱ្យស្ថាប័ននីតិប្រតិបត្តិទទួលខុសត្រូវលើការប្រើប្រាស់ធនធានសាធារណៈទាំងនេះឡើយ។

អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាលើកទីមួយត្រូវបានធ្វើនៅក្នុងឆ្នាំ២០០៥ ដែលលទ្ធផលរបស់វាត្រូវបានផ្សព្វផ្សាយក្នុងឆ្នាំ២០០៦ ហើយអង្កេតលើកទីពីរត្រូវបានធ្វើក្នុងឆ្នាំ២០០៧ ដែលលទ្ធផលរបស់វាត្រូវបានផ្សព្វផ្សាយក្នុងឆ្នាំ២០០៨។ អង្កេតនេះ ដែលជាមូលដ្ឋានក្នុងការគណនាសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា (OBI) នឹងត្រូវធ្វើរៀងរាល់ពីរឆ្នាំម្តង ដើម្បីពិនិត្យមើលឡើងវិញនូវវឌ្ឍនភាពដែលប្រទេសនានាសម្រេចបានពីគ្រាមួយទៅគ្រាមួយ និងផ្តល់នូវរង្វាស់ឯករាជ្យតែមួយគត់ ដែលមានលក្ខណៈអាចប្រៀបធៀបបាន និងទៀងទាត់ស្តីពីតម្លាភាព និងគណនេយ្យភាពថវិកានៅជុំវិញពិភពលោក។ ក្នុងឆ្នាំ២០០៩ IBP បានសហការជាមួយដៃគូសង្គមស៊ីវិលនៅក្នុងប្រទេសចំនួន ៩៤ ដើម្បីប្រមូលទិន្នន័យសម្រាប់ការធ្វើអង្កេតលើកទីបីរបស់ខ្លួន។ ដូចនៅក្នុងការធ្វើអង្កេតមុនៗដែរ OBI ឆ្នាំ២០១០ វាយតម្លៃលើបរិមាណ និងប្រភេទនៃព័ត៌មានថវិកាដែលរដ្ឋាភិបាលនៃប្រទេសទាំង ៩៤ ផ្សព្វផ្សាយជាសាធារណៈនៅក្នុងឯកសារថវិកាសំខាន់ៗទាំងប្រាំបី ដែលគប្បីគួរត្រូវបានចេញផ្សាយនៅក្នុងឆ្នាំថវិកានីមួយៗ ដោយស្របតាមការប្រតិបត្តិល្អជាអន្តរជាតិស្តីពីតម្លាភាពថវិកា។ លទ្ធផលនៃអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១០ បានឆ្លុះបញ្ចាំងការស្រាវជ្រាវដែលធ្វើឡើងដោយអ្នកស្រាវជ្រាវសង្គមស៊ីវិលឯករាជ្យពីខែមិថុនា ដល់ខែកញ្ញា ឆ្នាំ២០០៩។ នេះគឺជាលើកទីពីរហើយដែលប្រទេសកម្ពុជា[2] បានចូលរួមក្នុងការធ្វើអង្កេតនេះ។ **សូមបញ្ជាក់ថា ព្រឹត្តិបត្រ សង្ខេបនេះ គឺធ្វើឡើងដោយផ្អែកជាចំបងលើរបកគំហើញសង្ខេបប្រចាំប្រទេសកម្ពុជា របាយការណ៍ស្តីពីអង្កេត OBS ឆ្នាំ២០១០ ទាំងមូលដែលផលិតដោយ IBP និងបច្ចុប្បន្នកម្មលើវឌ្ឍនភាពនៃតម្លាភាពថវិកាដែលបានសង្កេតឃើញតាំងពីពេលនោះមកដល់ខែឧសភា**

[2] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានចូលរួមក្នុងអង្កេតពិភពលោកនេះដើម្បីវាយតម្លៃវឌ្ឍនភាពដែលសម្រេចបានដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងពេលកន្លងមក។ អង្កេតនេះមានភាពផ្សារភ្ជាប់ផ្ទាល់ទៅនឹងផ្នែកតម្លាភាពនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ដែលក្នុងនោះមានការរាយនាមឯកសារថវិកាមួយចំនួន ដែលនឹងត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងឆ្នាំ ២០១០។ សម្រាប់ព័ត៌មានលម្អិតស្តីពីកម្មវិធីកែទម្រង់នេះ សូមមើលគេហទំព័ររបស់លេខាធិការដ្ឋានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ www.pfm.gov.kh។

**ឆ្នាំ២០១២ នេះ**។ ការបោះផ្សាយនូវព្រឹត្តិបត្រលើកនេះ គឺធ្វើឡើងដើម្បីឆ្លើយតបជាចំបងទៅនឹងតម្រូវការរបស់សធារណជន និងភាគីពាក់ព័ន្ធនានា បន្ទាប់ពីការផ្សព្វផ្សាយលើកទីមួយនូវព្រឹត្តិបត្រសង្ខេបលើ OBI ឆ្នាំ២០១០ នេះនៅក្នុងឆ្នាំ២០១១។

## របកគំហើញសំខាន់ៗសម្រាប់កម្ពុជាក្នុងឆ្នាំ ២០១០

- *ប្រទេសកម្ពុជាទទួលបានពិន្ទុ ១៥ លើ ១០០ នៅក្នុងពិន្ទុ OBI ឆ្នាំ២០១០ ដែលមានកម្រិតប្រហែលមួយភាគបីនៃពិន្ទុមធ្យម (៤២) សម្រាប់ប្រទេសដែលបានធ្វើអង្កេតទាំង ៩៤។ ប្រទេសវៀតណាម (១៤) ជាប្រទេសតែមួយគត់ដែលមានពិន្ទុទាបជាងកម្ពុជានៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ដោយឡែក ប្រទេសថៃទទួលបានពិន្ទុមធ្យមប្រចាំតំបន់គឺ ៤២។*
- *ពិន្ទុរបស់កម្ពុជាបង្ហាញថា រាជរដ្ឋាភិបាលផ្តល់ជូនដល់សាធារណជននូវព័ត៌មានមិនគ្រប់គ្រាន់ស្តីពីសកម្មភាពថវិកា និងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិ។ ប្រការនេះធ្វើឱ្យមានការលំបាកដល់ប្រជាពលរដ្ឋក្នុងការទាមទារឱ្យរាជរដ្ឋាភិបាលមានគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងនេះ។*
- *ទោះជាយ៉ាងណាក្តី ពិន្ទុរបស់កម្ពុជាបានកើនឡើងពី ១១ ដល់ ១៥ ពីឆ្នាំ២០០៨ ដល់២០១០ ដោយសារនាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលបានចេញផ្សាយនូវសារាចរស្តីពីគោលការណ៍ណែនាំលើការរៀបចំសេចក្តីព្រាងច្បាប់ថវិកា (របាយការណ៍បុរេថវិកា) បានទាន់ពេលវេលា។*




ប្រទេសកម្ពុជាបានធ្វើឱ្យប្រសើរឡើងនូវពិន្ទុ OBI និងតម្លាភាពថវិការបស់ខ្លួនបើប្រៀបធៀបទៅនឹងលទ្ធផល OBS លើកទីមួយរបស់ខ្លួនក្នុងឆ្នាំ២០០៨។ ពិន្ទុ OBI របស់កម្ពុជាបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាផ្តល់ជូនដល់សាធារណជននូវព័ត៌មានមិនគ្រប់គ្រាន់ស្តីពីសកម្មភាព ថវិកា និងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិនៅក្នុងកំឡុងពេលនៃឆ្នាំថវិកា។ ប្រការនេះធ្វើឱ្យមានការលំបាកដល់ប្រជាពលរដ្ឋក្នុងការទាមទារឱ្យរដ្ឋាភិបាលរបស់ខ្លួនមានគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពោលគឺការប្រមូលចំណូល និងការប្រើប្រាស់ មូលនិធិសាធារណៈប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល និងក្នុងការមានឥទ្ធិពលលើគោល-នយោបាយដើម្បីកែលម្អសេវាកម្មដែលពួកគេទទួលបាន និងជាពិសេសគឺធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេ។

កម្ពុជាផលិត និងផ្សព្វផ្សាយជាសាធារណៈនូវឯកសារចំនួនបួនក្នុងចំណោមឯកសារថវិកាសំខាន់ៗចំនួនប្រាំពីរ ក្នុងនោះរួមមានៈ **របាយការណ៍បុរេថវិកា ច្បាប់ថវិកាដែលបានអនុម័ត របាយការណ៍ក្នុងឆ្នាំ** និង **របាយការណ៍ដំណាច់ឆ្នាំ**។ ឯកសារទាំងនេះភាគច្រើនអាចរកបាននៅក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (www.mef.gov.kh) ខណៈដែលឯកសារស្តីពី ការគ្រប់គ្រងថវិកាដទៃទៀតអាចស្នើសុំបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរកបាននៅក្នុងសៀវភៅរាជកិច្ចរបស់រាជរដ្ឋាភិបាលដែលត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ។ ឯកសារថវិកាបីផ្សេងទៀតដែលមិនមានផ្សាយជាសាធារណៈរួមមានៈ **សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ របស់រដ្ឋាភិបាល របាយការណ៍សវនកម្ម** និង **របាយការណ៍អនុវត្តច្បាប់ថវិកាពាក់កណ្តាលឆ្នាំ**។ ប្រទេសកម្ពុជា ដូចប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ដែរ មិនមានផលិតឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋទេ។ អ្វីដែលសំខាន់គឺថា ទោះបីជារបាយការណ៍សវនកម្មដែលបង្កើតដោយស្ថាប័នសវនកម្មកំពូល ឬអាជ្ញាធរសវនកម្មជាតិត្រូវបានផ្សព្វផ្សាយក្តី ក៏ពេលវេលានៃការផ្សព្វផ្សាយមានការយឺតយ៉ាវខ្លាំង ដោយផ្អែកលើមាត្រដ្ឋាននៃការប្រតិបត្តិល្អជាអន្តរជាតិ ដែលតម្រូវឱ្យការបញ្ចេញនូវរបាយការណ៍សវនកម្មធ្វើឡើងយ៉ាងយូរបំផុតក្នុងរង្វង់ពីរឆ្នាំក្រោយឆ្នាំថវិកា។

ចំណាត់ថ្នាក់តម្លាភាពថវិកាអន្តរជាតិឆ្នាំ២០១០ នៃប្រទេសកម្ពុជាត្រូវបានចាត់ថ្នាក់នៅក្នុងចំណោមក្រុមប្រទេសចំនួន ២២ ដែលផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ជូនដល់សាធារណជន។ ប្រទេសកម្ពុជាមានពិន្ទុស្មើគ្នានឹងសាធារណៈរដ្ឋគៀហ្សិស ខណៈដែលប្រទេសចំនួន ១៩ មានពិន្ទុទាបជាង ហើយប្រទេសចំនួន ៧៣ មានពិន្ទុជារួមខ្ពស់ជាងកម្ពុជាដោយផ្អែកលើសន្ទស្សន៍ដូចគ្នា។ សូមមើលតារាង១ ខាងក្រោមសម្រាប់លទ្ធផលលម្អិតបន្ថែមទៀតនៃការផ្សព្វផ្សាយឯកសារថវិកានីមួយៗសម្រាប់កម្ពុជា។

**តារាង១: ភាពគ្រប់គ្រាន់ និង លទ្ធភាពរកបាននូវឯកសារថវិកាសំខាន់ៗចំនួនប្រាំបីក្នុងឆ្នាំ ២០០៩**

| **ឯកសារ** | **កម្រិតពិន្ទុនៃព័ត៌មាន*** | **ស្ថានភាពផ្សព្វផ្សាយ** |
|---|---|---|
| **របាយការណ៍បុរេថវិកា**<br>(សារាចររបស់រាជរដ្ឋាភិបាលស្តីពីគោលការណ៍ណែនាំលើការរៀបចំសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០១០) | B | **បានផ្សព្វផ្សាយ** |
| **សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល** (សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០១០) | E | **បានផលិត, មិនបានផ្សព្វផ្សាយ** |
| **ថវិកាដែលបានអនុម័ត** (ច្បាប់ថវិកា ឆ្នាំ ២០០៩) | B | **បានផ្សព្វផ្សាយ** |
| **ថវិកាសម្រាប់ប្រជាពលរដ្ឋ** | E | **មិនបានផលិត** |
| **របាយការណ៍ក្នុងឆ្នាំ**<br>(តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE) របស់រាជរដ្ឋាភិបាលឆ្នាំ ២០០៩) | B | **បានផ្សព្វផ្សាយ** |
| **របាយការណ៍ពាក់កណ្តាលឆ្នាំ (របាយការណ៍អនុវត្តច្បាប់ថវិកាពាក់កណ្តាលឆ្នាំ)** | E | **បានផលិត, មិនបានផ្សព្វផ្សាយ** |
| **របាយការណ៍ដំណាច់ឆ្នាំ** (TOFE ឆ្នាំ ២០០៩) | D | **បានផ្សព្វផ្សាយ** |
| **របាយការណ៍សវនកម្ម** | E | **បានផលិត, មិនបានផ្សព្វផ្សាយ** |

** ពិន្ទុលើភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលបានផ្តល់នៅក្នុងឯកសារនីមួយៗ និងលទ្ធភាពទទួលបានព័ត៌មានត្រូវបានគណនាចេញពីពិន្ទុមធ្យមដែលបានទទួលពីកម្រងសំណួរនៃអង្កេត OBS ឆ្នាំ២០១០ ដែលទាក់ទិននឹងឯកសារនីមួយៗ។ ពិន្ទុមធ្យមក្នុងចន្លោះ ០-២០ (មានន័យថាផ្តល់ព័ត៌មានមិនគ្រប់គ្រាន់) ត្រូវបានផ្តល់ពិន្ទុ E, ពិន្ទុក្នុងចន្លោះ ២១-៤០ (ផ្តល់ព័ត៌មានតិចតួច) ត្រូវបានផ្តល់ពិន្ទុ D, ពិន្ទុក្នុងចន្លោះ ៤១-៦០ (ផ្តល់ព័ត៌មានខ្លះ) ត្រូវបានផ្តល់ពិន្ទុ C, ពិន្ទុក្នុងចន្លោះ ៦១-៨០ (ផ្តល់ព័ត៌មានច្រើន) ត្រូវបានផ្តល់ពិន្ទុ B, និងពិន្ទុក្នុងចន្លោះ ៨១-១០០ (ផ្តល់ព័ត៌មានបរិបូរណ៍) ត្រូវបានផ្តល់ពិន្ទុ A ។*

**របាយការណ៍បុរេថវិកា** ផ្តល់ព័ត៌មាន (ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឆ្នាំមុន និងឆ្នាំបច្ចុប្បន្ន និងព្យាករណ៍សម្រាប់ឆ្នាំថវិកា ឬឆ្នាំសារពើពន្ធបន្ទាប់) ដែលផ្សារភ្ជាប់គោលនយោបាយរបស់រដ្ឋាភិបាលទៅនឹងថវិកា។ របាយការណ៍នេះគប្បីត្រូវបានផ្សព្វផ្សាយមុនសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល និងជាទូទៅដាក់ចេញនូវប៉ារ៉ាម៉ែត្រទូលំទូលាយដែលកំណត់ពីថវិកា របស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំបន្ទាប់។ ប្រទេសកម្ពុជាផ្សព្វផ្សាយ **សារាចររបស់រាជរដ្ឋាភិបាលស្តីពីគោលការណ៍ណែនាំលើការរៀបចំសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ** (របាយការណ៍បុរេថវិកា) នៅក្នុងរាជកិច្ច[៣] ចាប់តាំងពីឆ្នាំ២០០៩មក ដែលអាចរកបានជាសាធារណៈដោយបង់ថ្លៃតិចតួច។

**សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល** ឬសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ គឺជាឧបករណ៍គោលនយោបាយដ៏សំខាន់បំផុតរបស់រដ្ឋាភិបាល។ ឯកសារនេះ បង្ហាញពីរបៀបដែលរដ្ឋាភិបាលគ្រោងប្រមូលចំណូលតាមរយៈពន្ធ និងប្រភពផ្សេងទៀត និងចំណាយថវិកាទាំងនេះដើម្បីគាំទ្រវិស័យអាទិភាពរបស់ខ្លួន ដើម្បីបម្លែងគោលដៅនៃគោលនយោបាយឱ្យទៅជាសកម្មភាព។

[៣] រាជកិច្ច និងឯកសារថវិកាផ្សេងទៀតដែលត្រូវបានដាក់បញ្ចូលក្នុងអង្កេត OBS នេះអាចរកជាវបាននៅការិយាល័យនៃអគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រដែលស្ថិតក្រោមទីស្តីការគណៈរដ្ឋមន្ត្រី នៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬទាញយកពីគេហទំព័រថវិកាកម្ពុជា www.cambodianbudget.org ។

នៅប្រទេសកម្ពុជា **សេចក្តីព្រាងច្បាប់ថវិកា** ត្រូវបានផលិតសម្រាប់ប្រើប្រាស់ផ្ទៃក្នុង និងមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយស្ថាប័ននីតិប្រតិបត្តិសម្រាប់សាធារណជន ស្របតាមការប្រតិបត្តិល្អជាអន្តរជាតិនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឡើយ ថ្វីបើឯកសារនេះត្រូវបានស្ថាប័ននីតិបញ្ញត្តិផ្តល់ជូនដល់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូចសម្រាប់ធ្វើការវិភាគក្តី។ នៅខែវិច្ឆិកា ឆ្នាំ២០១០ សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១១ ត្រូវបានផ្តល់តាមសំណើមកឱ្យវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ប៉ុន្តែសេចក្តីព្រាងច្បាប់ថវិកា ឆ្នាំ២០១២ មិនត្រូវបានបញ្ចេញទេបើទោះជាមានការស្នើសុំច្រើនលើកក្តី។

**ថវិកាដែលបានអនុម័ត** ក្លាយជាច្បាប់របស់ប្រទេស និងផ្តល់នូវព័ត៌មានមូលដ្ឋានសម្រាប់ការវិភាគថវិកាទាំងអស់ដែលធ្វើនៅក្នុងឆ្នាំថវិកានេះ។ ដូច្នេះវាគឺជាចំណុចចាប់ផ្តើមនៃកិច្ចប្រឹងប្រែងទាំងឡាយដើម្បីតាមដានការអនុវត្តន៍ច្បាប់ថវិកា។ ជាទូទៅ ថវិកាដែលបានអនុម័តគួរតែផ្តល់ជូនសាធារណជននូវទិន្នន័យដែលគេអាចប្រើប្រាស់បាន ដើម្បីវាយតម្លៃអាទិភាពគោលនយោបាយរបស់រដ្ឋាភិបាល និងទាមទារឱ្យរដ្ឋាភិបាលទទួលខុសត្រូវលើការអនុវត្តន៍ថវិកា។ ប្រទេសកម្ពុជាផ្សព្វផ្សាយច្បាប់ថវិកា ឬច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ (ថវិកាដែលបានអនុម័ត) ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រម នៅក្នុងសៀវភៅរាជកិច្ចរបស់រាជរដ្ឋាភិបាល ប៉ុន្តែឯកសារនេះមិនមានដាក់បញ្ចូលព័ត៌មានលម្អិតកម្រិតថ្នាក់កម្មវិធីនៅក្នុងផ្នែកចំណាយនៅឡើយទេ។ ច្បាប់ថវិកាអាចទាញយកបានពីគេហទំព័ររបស់រដ្ឋសភាជាតិ[៣] ប៉ុន្តែ មានតែច្បាប់ថវិកាដែលបានអនុម័តក្នុងអាណត្តិទីមួយ ទីពីរ និងទីបីទេដែលអាចទាញយកបាន។ គេសង្ឃឹមថាច្បាប់ដែលបានអនុម័តក្នុងអាណត្តិទីបួន (២០០៨-បច្ចុប្បន្ន) នឹងអាចទាញយកបាននាពេលដ៏ខ្លីខាងមុខ។ ម៉្យាងទៀត ច្បាប់ថវិកា[៤] មួយចំនួនល្មមគ្រាន់បើ ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០០៩ បើទោះជាឆ្នាំខ្លះមិនមានក្តី ត្រូវបានគេសង្កេតឃើញថាអាចទាញយកបានពីគេហទំព័ររបស់នាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (http://www.tax.gov.kh/taxtypes.php)។

**ថវិកាសម្រាប់ប្រជាពលរដ្ឋ** គឺជាការបង្ហាញដែលមិនមានលក្ខណៈបច្ចេកទេស (ឯកសារសម្រាយមានលក្ខណៈសាមញ្ញ) នៃថវិការបស់រដ្ឋាភិបាល ដែលមានគោលបំណងជួយឱ្យប្រជាពលរដ្ឋ (រួមទាំងអ្នកដែលមិនធ្លាប់ដឹងឮអំពីហិរញ្ញវត្ថុសាធារណៈ) អាចយល់ដឹងអំពីផែនការរបស់រដ្ឋាភិបាលក្នុងការប្រមូលចំណូល និងចំណាយមូលនិធិសាធារណៈទាំងនេះ។ ដូចបណ្តាប្រទេសទាំងអស់ផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ ដែលត្រូវបានរាប់បញ្ចូលក្នុងអង្កេតនេះដែរ ប្រទេសកម្ពុជាមិនមានផលិតឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋទេ។ ថ្វីបើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្លាប់បានផលិតម្តងនូវ "ថវិកាសង្ខេប" ដែលបង្ហាញពីតួលេខសរុបខ្លះៗស្តីពីចំណូល ចំណាយ និងសូចនាករម៉ាក្រូសេដ្ឋកិច្ចនៅក្នុងឆ្នាំ២០០៧ក្តី ក៏ឯកសារនេះមិនត្រូវបានបោះផ្សាយជាបន្តទៀតទេដោយសារកង្វះថវិកា។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា មានជំនឿថាការបោះផ្សាយនូវឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋអាចជួយលើកកម្ពស់តម្រូវការសាធារណៈសម្រាប់ព័ត៌មានថវិកា និងការចូលរួមរបស់សាធារណជនយ៉ាងសកម្មក្នុងដំណើរការថវិកា និងការត្រួតពិនិត្យថវិកា។

ពាក់ព័ន្ធនឹងទិដ្ឋភាពបច្ចេកទេសនៃថវិកា មិនត្រឹមតែការយល់ដឹងរបស់សាធារណជនទេដែលត្រូវបានរារាំងដោយអវត្តមាននៃឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋ សូម្បីតែភាគីពាក់ព័ន្ធនានាដូចជាអង្គការសង្គមស៊ីវិលដែលធ្វើការតស៊ូមតិលើបញ្ហាថវិកាក៏ជួបប្រទះនូវការលំបាកក្នុងការស្វែងយល់អំពីលក្ខណៈបច្ចេកទេសនៃថវិកាដែរ ដោយសារកង្វះនូវឯកសារណែនាំសម្រាយស្តីពីដំណើរការថវិកាជាតិ និងពាក្យពេចន៍បច្ចេកទេសថវិកា។ ដូចដែលបានសង្កេតកន្លងមក មិនមានសន្ទានុក្រម ឬវចនានុក្រម (ខ្មែរ) ស្តីពីពាក្យពេចន៍បច្ចេកទេសថវិកាត្រូវបានផលិតឡើងសម្រាប់ផ្សព្វផ្សាយជាសាធារណៈ ឬជួយជម្រុញការចូលរួមជាសាធារណៈទេ លើកលែងតែពាក្យពេចន៍គន្លឹះ និងពាក្យពេចន៍ថវិកាមួយចំនួនតូចដែលត្រូវបានពន្យល់នៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងប្រកាសលេខ១៤៤៨ សហវ.ប្រ.ក របស់

---

[៣] រហូតមកដល់ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២។

[៤] ច្បាប់ថវិកាឆ្នាំ២០១០ ត្រូវបានទុកដោយឡែកនៅលើគេហទំព័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុវិញ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ។ ដោយមិនរាប់បញ្ចូលនូវឯកសារទាំងឡាយដែលយើងមិនអាចដឹងអស់ ឯកសារទាំងពីរនេះប្រហែលជាសន្ទានុក្រម ឬឯកសារណែនាំដែលអាចរកបានជាសាធារណៈតែពីរគត់សម្រាប់អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋអាន និងយល់អំពីចំណាត់ថ្នាក់ថវិកា ដើម្បីដោះស្រាយបញ្ហាប្រឈមផ្នែកបច្ចេកទេសមួយផ្នែកនៅក្នុងការងារតាមដានថវិកា។ គេបានដឹងថា ការរៀបចំចងក្រងសន្ទានុក្រម[៥] ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងដំណើរការ។ ការបោះផ្សាយនូវឯកសារណែនាំរបៀបនេះ ប្រសិនបើធ្វើឡើងបានឆាប់រហ័ស អាចនឹងជួយបង្កើនការចូលរួមនៃភាគីមិនមែនរដ្ឋាភិបាលនៅក្នុងដំណើរការថវិកាបន្ថែមទៀត ក៏ដូចជាសមត្ថភាពរបស់ក្រសួង/ស្ថាប័នសាមីក្នុងការពន្លឿនកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ អ្វីដែលសំខាន់ជាងនេះទៀត គឺថាឯកសារទាំងនេះដែលអាចបម្រើជាកាតាលីករដ៏សំខាន់មួយក្នុងការលើកកម្ពស់តម្រូវការសាធារណៈសម្រាប់ព័ត៌មានថវិកាបន្ថែមទៀត ការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការថវិកា និងការទាមទារឱ្យក្រសួងសាមីទទួលខុសត្រូវលើការគ្រប់គ្រងថវិកា គប្បីត្រូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនជាទូទៅ។

**របាយការណ៍ក្នុងឆ្នាំ** ផ្តល់នូវរបាយការណ៍សង្ខេបមួយអំពីប្រសិទ្ធភាពនៃការអនុវត្តថវិកាក្នុងរយៈពេលមួយនៅក្នុងឆ្នាំថវិកា។ គោលបំណងចម្បងនៃការផ្សព្វផ្សាយរបាយការណ៍ក្នុងឆ្នាំ គឺសំដៅផ្តល់ការវាស់វែងទៀងទាត់មួយលើនិន្នាការនៃការប្រមូលចំណូល និងចំណាយជាក់ស្តែងដែលអនុញ្ញាតឱ្យមានការប្រៀបធៀបជាមួយតួលេខនៅក្នុងច្បាប់ថវិកា និងការកែតម្រូវ។ តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE) ឬតារាងស្តីពីការអនុវត្តថវិការដ្ឋ (របាយការណ៍ក្នុងឆ្នាំ) របស់កម្ពុជា ផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយខ្លះៗ។ ប៉ុន្តែ តារាងនេះខ្វះសេចក្តីលម្អិតសំខាន់ៗខ្លះដូចជា បំណែងចែកចំណាយតាមក្រសួងសាមី ការពន្យល់លម្អិតអំពីភាពខុសគ្នារវាងចំណូល និងចំណាយជាក់ស្តែង និងក្នុងផែនការ ព្រមទាំងការធ្វើបច្ចុប្បន្នកម្ម ឬការចេញផ្សាយជាទៀងទាត់លើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ពេលវេលានៃការផ្សព្វផ្សាយ TOFE ប្រចាំខែនីមួយៗមិនមានភាពទៀងទាត់ទេ ជួនកាលឯកសារនេះត្រូវបានចេញផ្សាយលើសពីពីរខែក្រោយខែដែលត្រូវបានរាយការណ៍។ ការចេញផ្សាយយឺតនេះ អាចបណ្តាលជាចំបងមកពីតម្រូវការពេលវេលាសម្រាប់ការសម្របសម្រួល និងការបញ្ជាក់តួលេខតាមនាយកដ្ឋាននានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាសម្រាប់ការអនុម័តរបស់គណៈគ្រប់គ្រងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅលើ TOFE ប្រចាំខែមុននឹងចេញផ្សាយនៅលើគេហទំព័រសម្រាប់ការប្រើប្រាស់ជាផ្លូវការ[៦]។

**របាយការណ៍ពាក់កណ្តាលឆ្នាំ** ផ្តល់នូវទស្សនៈរួមមួយអំពីប្រសិទ្ធភាពនៃការអនុវត្តថវិកានៅពាក់កណ្តាលឆ្នាំថវិកា។ ព័ត៌មាននៅក្នុងរបាយការណ៍នេះអនុញ្ញាតឱ្យគេវាយតម្លៃស្ថានភាពសារពើពន្ធរបស់រដ្ឋាភិបាល ដោយប្រៀបធៀបនឹងផែនការដែលបានដាក់ចេញនៅក្នុងច្បាប់ថវិកាដើម។ វាអនុញ្ញាតឱ្យរដ្ឋាភិបាល ស្ថាប័ននីតិប្បញ្ញត្តិនិងសាធារណជន ពិនិត្យមើលថាតើគួរធ្វើការកែតម្រូវឬទេ ទាក់ទិននឹងចំណូលចំណាយ ឬកម្ចីនៅក្នុងរយៈពេលប្រាំមួយខែចុងក្រោយនៃឆ្នាំថវិកា។

នៅកម្ពុជា មានតែមាត្រា៨៤ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលតម្រូវឱ្យផ្សព្វផ្សាយគ្រប់របាយការណ៍ហិរញ្ញវត្ថុ និងគណនេយ្យជាសាធារណៈ។ ទោះជាយ៉ាងណាក្តី នៅខែកញ្ញា ឆ្នាំ២០១០ រាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបោះផ្សាយនូវរបាយការណ៍ពាក់កណ្តាលឆ្នាំនៃការអនុវត្តច្បាប់ថវិកាឆ្នាំ២០១០ ព្រមជាមួយនឹងឯកសារស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០០០-២០១១ នៅលើគេហទំព័ររបស់ខ្លួន។ នេះគឺស្តែងពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការធ្វើឱ្យប្រសើរឡើងនូវតម្លាភាពថវិកា បើទោះបីជាមាត្រា៣៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈតម្រូវត្រឹមតែឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់នូវរបាយការណ៍នេះ និង

---

[៥] ដោយយោងតាមព័ត៌មានពីរបាយការណ៍វឌ្ឍនភាពត្រីមាសទី១ ឆ្នាំ២០១២ ស្តីពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលទាញយកពីវែបសាយ www.pfm.gov.kh នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២។

[៦] ព័ត៌មានទទួលបានពីជំនួបរវាងបុគ្គលិកនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

របាយការណ៍ដំណាច់ឆ្នាំដល់រដ្ឋសភា និងព្រឹទ្ធសភានៅពាក់កណ្តាលឆ្នាំ និងនៅពេលពិភាក្សាអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំក្តី។ ការផ្សព្វផ្សាយនេះក៏បង្ហាញផងដែរនូវជំហានវិជ្ជមានមួយរបស់រាជរដ្ឋាភិបាលដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការរួមបញ្ចូលសាធារណជនទៅក្នុងដំណើរការថវិកា ទោះបីមាន ឬមិនមានតម្រូវការពីសាធារណជន ដែលតម្រូវការនេះអាចនៅមានកម្រិតទាបនាពេលបច្ចុប្បន្ន តែកំពុងនឹងកើនឡើងជាលំដាប់។ ប្រសិនបើគំនិតផ្តួចផ្តើមនេះបន្តមានក្នុងលក្ខណៈជាប្រព័ន្ធ ប្រទេសកម្ពុជាទំនងជាអាចធ្វើឱ្យប្រសើរឡើងនូវលទ្ធផលជារួមរបស់ខ្លួននៅក្នុងអង្កេត OBS លើកក្រោយទៀត។ រហូតមកដល់ពេលបច្ចុប្បន្ន របាយការណ៍ពាក់កណ្តាលឆ្នាំនៃការអនុវត្តច្បាប់ថវិកាឆ្នាំ២០១១ មិនទាន់ត្រូវបានចេញផ្សាយនៅឡើយទេ។ ការផ្សព្វផ្សាយនូវរបាយការណ៍ពាក់កណ្តាលឆ្នាំនេះ ក៏ដូចជាឯកសារថវិកាដទៃទៀតអាចដាក់នូវបន្ទុកហិរញ្ញវត្ថុតិចតួច ឬមិនមានសោះ ដល់រាជរដ្ឋាភិបាល។

**របាយការណ៍ដំណាច់ឆ្នាំ** មានព័ត៌មានដែលប្រៀបធៀបការអនុវត្តថវិកាជាក់ស្តែងនៅក្នុងឆ្នាំថវិកាទៅនឹងច្បាប់ថវិកាដែលបានអនុម័ត។ របាយការណ៍ដំណាច់ឆ្នាំអាចផ្តល់ព័ត៌មានដល់សាធារណជន និងអ្នកធ្វើគោលនយោបាយអំពីគោលនយោបាយពន្ធ និងកាតព្វកិច្ចបំណុល ក៏ដូចជាអាទិភាពចំណាយធំៗសម្រាប់ឆ្នាំថវិកាខាងមុខ។ ម្យ៉ាងទៀត ព័ត៌មានដែលមាននៅក្នុងរបាយការណ៍នេះអាចជួយក្រសួងស្ថាប័ននីមួយៗ និងសាធារណជនក្នុងការកំណត់គុណវិបត្តិនានានៅក្នុងគោលនយោបាយ និងកម្មវិធីដែលមានស្រាប់ ហើយអាចប្រើបានដើម្បីធ្វើឱ្យមានឥទ្ធិពលលើទិសដៅអនាគត។ នៅប្រទេសកម្ពុជា TOFE (របាយការណ៍ដំណាច់ឆ្នាំដែលមិនបានឆ្លងកាត់ការធ្វើសវនកម្ម) ត្រូវបានគេកត់សម្គាល់ថាបានចេញផ្សាយនៅក្នុងខែទីប្រាំ ឬទីប្រាំមួយនៃឆ្នាំសារពើពន្ធបន្ទាប់ នៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទោះយ៉ាងណាក៏ដោយ ក៏ទម្រង់នៃមាតិកាថវិកាដែលប្រើក្នុងឯកសារនេះ ក៏ដូចជាក្នុងរបាយការណ៍ពាក់កណ្តាលឆ្នាំ និងទម្រង់នៃមាតិកាថវិកាដែលប្រើក្នុងច្បាប់ថវិកា រួមទាំងច្បាប់ទូទាត់ថវិកាផង មិនមានសង្គតិភាពទេ។ ប្រការនេះធ្វើឱ្យមានការលំបាកដល់សារធារណជន និងអង្គការសង្គមស៊ីវិល ក្នុងការត្រួតពិនិត្យការអនុវត្តថវិកា សំដៅទាមទារឱ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះការអនុវត្តថវិកា។ ទាំងរបាយការណ៍ពាក់កណ្តាលឆ្នាំ និងរបាយការណ៍ដំណាច់ឆ្នាំ គឺជាតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE) ដែលបានអនុម័តឱ្យចេញផ្សាយនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បន្ថែមលើ TOFE ដែលបានអនុម័តឱ្យចេញផ្សាយនៅលើគេហទំព័រនេះ គឺមានបំណែងចែកសរុបនៃតួលេខអនុវត្តថវិកាតាមក្រសួងសាមី និង TOFE ដែលបានធ្វើបច្ចុប្បន្នកម្មច្រើនជាង ត្រូវបានបញ្ចូលទៅក្នុងព្រឹត្តិប័ត្រស្ថិតិប្រចាំខែ[7] ហើយអាចរកជាវបាននៅនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តួលេខទាំងនេះ គឺជាតួលេខបណ្តោះអាសន្នដែលភាគច្រើនប្រមូលមកពីអគ្គនាយកដ្ឋានរតនាគារជាតិ ប៉ុន្តែយ៉ាងណាក្តីក៏មានបញ្ហាកំហុសតួលេខ ជាពិសេសនៅលើបំណែងចែកសរុបនៃតួលេខអនុវត្តថវិកាតាមក្រសួងសាមី ដែលរាយការណ៍នៅក្នុងព្រឹត្តិប័ត្រស្ថិតិប្រចាំខែសម្រាប់ឆ្នាំ២០១០ ដោយប្រៀបធៀបទៅនឹងតួលេខដែលរាយការណ៍នៅក្នុងឯកសារស្តីពីការគ្រប់គ្រងថវិកាភាគ១ (ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង: ច្បាប់ និងបទប្បញ្ញត្តិ) ឆ្នាំ២០១១ និង ២០១២។

**របាយការណ៍សវនកម្ម** គឺជាការវាយតម្លៃឯករាជ្យមួយលើគណនីរបស់រដ្ឋាភិបាល (ការប្រមូលចំណូល និងចំណាយ) ដោយស្ថាប័នសវនកម្មកំពូលរបស់ប្រទេស។ ឯកសារនេះរាយការណ៍ថាតើរដ្ឋាភិបាលបានប្រមូលចំណូល និងចំណាយថវិកាស្របតាមច្បាប់ថវិកាដែលបានអនុម័តឬទេ និងថាតើគណនីរបស់រដ្ឋាភិបាលគឺត្រឹមត្រូវ និងអាចពឹងផ្អែកក្នុងការផ្តល់នូវរូបភាពមួយដែលអាចទុកចិត្តបានអំពីស្ថានភាពសារពើពន្ធឬទេ។ របាយការណ៍សវនកម្មក៏ផ្តល់ព័ត៌មានផងដែរអំពីបញ្ហាទាំងឡាយណាដែលត្រូវបានរកឃើញដោយសវនករនៅក្នុងការគ្រប់គ្រងមូលនិធិសាធារណៈនៅក្នុងឆ្នាំថវិកា។ នៅប្រទេសកម្ពុជា របាយការណ៍សវនកម្មលើការអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាលតម្រូវឱ្យ

[7] ព្រឹត្តិប័ត្រស្ថិតិប្រចាំខែនេះមានតម្លៃ២០.០០០រៀល ឬ ៥ដុល្លារក្នុងមួយច្បាប់។

ដាក់ជូនទៅអង្គនីតិប្បញ្ញត្តិនៅមុនពេលការអនុម័តច្បាប់ទូទាត់ថវិការប្រចាំឆ្នាំ។ ទោះបីជារបាយការណ៍នេះត្រូវបានចាត់ទុកថាជាឯកសារសាធារណៈដោយមាត្រា២៩នៃច្បាប់ស្តីពីសវនកម្ម ក៏របាយការណ៍នេះអាចមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ ឬផ្សព្វផ្សាយដោយលុបចោលនូវព័ត៌មានពិស្តារប្រសិនបើឯកសារនេះមានព័ត៌មានដែលអាចចាត់ទុកថាផ្ទុយទៅនឹងផលប្រយោជន៍ជាតិ ឬផលប្រយោជន៍ពាណិជ្ជកម្មរបស់អង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល ដូចដែលបានចែងក្នុងមាត្រា៣៧ មាត្រា៣៨ និង មាត្រា៣៩ នៃច្បាប់នេះ។

ជាលើកទីមួយក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនចាប់តាំងពីពេលបង្កើតឡើងក្នុងឆ្នាំ២០០០ អាជ្ញាធរសវនកម្មជាតិ ដែលជាអន្តរជាតិសំដៅថាជាស្ថាប័នសវនកម្មកំពូលបានផ្សព្វផ្សាយរបាយការណ៍សវនកម្មស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(ការអនុវត្តថវិកា)ឆ្នាំ២០០៦ នៅក្នុងខែកញ្ញា ឆ្នាំ២០០៩ (ស្ទើរតែ៣ឆ្នាំបន្ទាប់ពីឆ្នាំសារពើពន្ធ) និង របាយការណ៍សវនកម្មស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៧ ក្នុងខែតុលា ឆ្នាំ២០១១ (ស្ទើរតែ៤ឆ្នាំបន្ទាប់ពីឆ្នាំសារពើពន្ធ)។ ដោយសាររបាយការណ៍នេះត្រូវបានផ្សព្វផ្សាយ ឬផ្តល់ជូនសាធារណជនទៅតាមសំណើមានរយៈពេលយឺតជាងពីរឆ្នាំក្រោយពេលបញ្ចប់ឆ្នាំសារពើពន្ធនោះ ឯកសារនេះមិនបានបំពេញតាមស្តង់ដារអប្បបរិមានៃការប្រតិបត្តិល្អជាអន្តរជាតិទេ និងយោងតាមវិធីសាស្ត្រនៃអង្កេត OBS របាយការណ៍នេះត្រូវបានចាត់ទុកថា "**បានផលិត ប៉ុន្តែមិនបានផ្សព្វផ្សាយជាសាធារណៈ**"។ នាពេលអនាគត ការផ្សព្វផ្សាយរបាយការណ៍សវនកម្មឱ្យបានទាន់ពេលវេលា នឹងរឹតតែធ្វើឱ្យប្រសើរឡើងនូវតម្លាភាពជាទូទៅនៃដំណើរការថវិកា ធានានូវឯករាជ្យភាពរបស់អាជ្ញាធរសវនកម្មជាតិ និងបង្កើនពិន្ទុ OBI របស់កម្ពុជាបន្ថែមទៀត។

## ការចូលរួមរបស់សាធារណជន និងស្ថាប័នដែលធានានូវគណនេយ្យភាព

ក្រៅពីការធ្វើឱ្យប្រសើរឡើងថែមទៀតនូវលទ្ធភាពរកបាន និងភាពគ្រប់ជ្រុងជ្រោយនៃឯកសារថវិកាសំខាន់ៗ ក៏មានវិធីផ្សេងទៀតដែរ ដែលអាចធ្វើឱ្យដំណើរការថវិការបស់កម្ពុជារឹតតែមានលក្ខណៈបើកចំហបន្ថែមទៀត។ វិធីទាំងនេះ រួមមានការធានាឱ្យបាននូវវត្តមានស្ថាប័ននីតិប្បញ្ញត្តិនិងអាជ្ញាធរសវនកម្មជាតិដ៏រឹងមាំមួយ ដែលផ្តល់ការត្រួតពិនិត្យតាមដានថវិកាប្រកបដោយប្រសិទ្ធភាព ក៏ដូចជាការផ្តល់ឱកាសឱ្យកាន់តែទូលំទូលាយថែមទៀតសម្រាប់ការចូលរួមរបស់សាធារណជននៅក្នុងដំណើរការថវិកា។

**តារាង២: ការវាយតម្លៃលើភាពខ្លាំងនៃស្ថាប័នត្រួតពិនិត្យ**

| ស្ថាប័នត្រួតពិនិត្យ | ភាពខ្លាំង** |
|---|---|
| ស្ថាប័ននីតិបញ្ញត្តិ | ខ្សោយ |
| ស្ថាប័នសវនកម្មកំពូល | ខ្សោយ |

**ភាពខ្លាំងរបស់ស្ថាប័ននីតិប្បញ្ញត្តិនិងស្ថាប័នសវនកម្មកំពូលត្រូវបានគណនាចេញពីពិន្ទុមធ្យមដែលបានទទួលពីកម្រងសំណួរនៃអង្កេត OBS ឆ្នាំ២០១០ ដែលទាក់ទិននឹងស្ថាប័ននីមួយៗ។ ពិន្ទុមធ្យមក្នុងចន្លោះ ០-៣៣ ត្រូវបានចាត់ថ្នាក់ថាខ្សោយ ចន្លោះ៣៤-៦៦ ជាបង្គួរ និង ៦៧-១០០ ជាខ្លាំង។

យោងតាមអង្កេត OBS ការត្រួតពិនិត្យថវិកាដែលធ្វើដោយស្ថាប័ននីតិបញ្ញត្តិកម្ពុជាគឺនៅមានលក្ខណៈខ្សោយ ដោយសារស្ថាប័ននេះមិនទាន់:(១)មានអំណាចពេញលេញក្នុងការធ្វើវិសោធនកម្មលើសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលមុនពេលចាប់ផ្តើមឆ្នាំថវិកាថ្មី(២) ពេលវេលាគ្រប់គ្រាន់ដូចដែលត្រូវបានកំណត់ដោយស្តង់ដារនៃការប្រតិបត្តិល្អជាអន្តរជាតិសម្រាប់ពិភាក្សា និងអនុម័តថវិកា និង (៣) ធ្វើសវនាការសាធារណៈដែលអាចឱ្យសាធារណជន និងអង្គការសង្គមស៊ីវិលផ្តល់សក្ខីកម្មអំពីអាទិភាពទាំងឡាយនៅក្នុងសេចក្តីព្រាងច្បាប់ថវិការបស់រាជរដ្ឋាភិបាល (ពោលគឺការពិភាក្សារវាងស្ថាប័ននីតិប្រតិបត្តិ និងគណៈកម្មការទីពីរនៃរដ្ឋសភាស្តីពីសេចក្តីព្រាងច្បាប់ថវិកា)។ នៅប្រទេសកម្ពុជា ក៏ដូចជានៅប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ីដែរ ការពិភាក្សាអំពីថវិកាមានលក្ខណៈស្ទើរតែបិទជិត ដោយយោងទៅតាមការប្រតិបត្តិល្អជាអន្តរជាតិ ដោយពុំទាន់មានការធ្វើសវនាការជាសាធារណៈទេ។

ម្យ៉ាងទៀត ស្ថាប័ននីតិបញ្ញត្តិរបស់កម្ពុជាហាក់ដូចជាត្រូវបានរារាំងដោយសារកង្វះព័ត៌មានថវិកា ដើម្បីអនុញ្ញាតឱ្យមានការពិភាក្សាវិភាគវែកញែកទៅលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងអំឡុងពេលអនុម័តច្បាប់ថវិកា។ ដូចដែលបានសង្កេតឃើញក្នុងពេលកន្លងមក ព័ត៌មានថវិកាដែលធ្លាប់ដាក់ជូនទៅរដ្ឋសភាត្រូវបានកាត់បន្ថយច្រើន។ ចាប់តាំងពីឆ្នាំ២០១០មក តួលេខនៃការប៉ាន់ស្មានការអនុវត្ត

ថវិកាសម្រាប់ឆ្នាំសារពើពន្ធមុនត្រូវបានលុបចេញពីសេចក្តីព្រាងច្បាប់ថវិកា ដោយទុកតែតួលេខវិភាជន៍សុទ្ធសាធសម្រាប់រដ្ឋសភាអនុម័ត ហើយតារាងសង្ខេបស្តីពីការអនុវត្តថវិកាសម្រាប់ឆ្នាំមុនៗ ដែលរៀបតាមទម្រង់មាតិកាថវិកាផ្សេងៗ ក៏ដូចជាព័ត៌មានអំពីចំនួនបុគ្គលិកហាក់ដូចជាត្រូវបានដកចេញពីសេចក្តីថ្លែងហេតុដែលភ្ជាប់ទៅជាមួយនឹងច្បាប់ថវិកាទាំងឡាយ។ បន្ថែមលើនេះផងដែរ របាយការណ៍ពាក់កណ្តាលឆ្នាំនៃការអនុវត្តច្បាប់ថវិកាឆ្នាំ២០១០ ដែលបានដាក់ជូនទៅរដ្ឋសភា និងត្រូវបានចេញផ្សាយលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្តល់ត្រឹមតែព័ត៌មានថវិកាសរុប ដោយមិនមានភ្ជាប់ជាមួយនូវតួលេខនានាស្តីពីការអនុវត្តថវិកាលម្អិតសម្រាប់ឱ្យសមាជិកសភា ធ្វើការពិនិត្យឡើងវិញឱ្យបានហ្មត់ចត់ឡើយ។ ការរារាំងទាំងនេះអាចដាក់កម្រិតលើសមត្ថភាពរបស់សមាជិកសភាក្នុងការយល់ដឹងឱ្យកាន់តែស៊ីជម្រៅមួយអំពីស្ថានភាព និងបញ្ហាថវិកា ដែលប្រការនេះអាចនឹងមិនជួយជម្រុញឱ្យមានការពិភាក្សាវែកញែកទៅលើច្បាប់ថវិកាឥច្រើនទេ ក៏ដូចជាមិនជួយជម្រុញឱ្យមានការត្រួតពិនិត្យ និងតាមដានថវិកាប្រកបដោយប្រសិទ្ធភាពពីសំណាកសមាជិកសភាដែរ។

សាធារណជនគប្បីត្រូវបានផ្តល់ឱកាសឱ្យចូលរួមដោយផ្ទាល់ជាមួយស្ថាប័នសវនកម្មកំពូល នៅក្នុងដំណាក់កាលវាយតម្លៃលើដំណើរការថវិកា។ គេឃើញមានយន្តការជាច្រើនសម្រាប់ការផ្តល់មតិយោបល់ប្រតិកម្មសំខាន់ៗដូចជា "ខ្សែទូរស័ព្ទសម្រាប់រាយការណ៍ពីអំពើមិនត្រឹមត្រូវនៃការអនុវត្តថវិកា (ចំណូល និងចំណាយ)" ជាដើម។ យោងតាមអង្កេត OBS ការត្រួតពិនិត្យថវិកាដែលធ្វើឡើងដោយអាជ្ញាធរសវនកម្មជាតិ កម្ពុជាគឺមានលក្ខណៈខ្សោយដោយសារអាជ្ញាធរនេះមិនទាន់: (១) មានធនធានហិរញ្ញវត្ថុ និងធនធានមនុស្សគ្រប់គ្រាន់សម្រាប់បំពេញភារកិច្ចរបស់ខ្លួនប្រកបដោយអត្ថន័យ (២) ចេញផ្សាយរបាយការណ៍សវនកម្មស្តីពីចំណាយចុងក្រោយនៃក្រសួង/ស្ថាប័នជាតិឱ្យបានទាន់ពេលវេលា (៣) មានបណ្តាញប្រាស្រ័យទាក់ទងសមស្របជាមួយសាធារណជន និង (៤) ចេញផ្សាយរបាយការណ៍ស្តីពីជំហានបន្តដែលស្ថាប័ននីតិប្រតិបត្តិត្រូវអនុវត្តដើម្បីឆ្លើយតបទៅនឹងអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជា ទីម័រខាងកើត និងវៀតណាម គឺជាប្រទេសបី ដែលស្ថាប័នសវនកម្មកំពូលនៅមិនទាន់បានបង្កើត ឬដាក់ឱ្យដំណើរការនូវការប្រាស្រ័យទាក់ទងរបៀបនេះនៅឡើយ។ ដូចដែលបានផ្តល់អនុសាសន៍ដោយ IBP រាជរដ្ឋាភិបាលកម្ពុជាគប្បីគួរទទួលស្គាល់ថា ការផ្សព្វផ្សាយព័ត៌មានថវិការបស់ខ្លួនមានន័យថាជាការពង្រឹងតួនាទីរបស់ស្ថាប័នត្រួតពិនិត្យ ក៏ដូចជាតួនាទីរបស់សាធារណជនផងដែរ។ សូម្បីតែព័ត៌មានត្រូវបានផ្តល់ដោយស្ថាប័ននីតិប្រតិបត្តិក្តី ក៏អវត្តមាននៃការត្រួតពិនិត្យនិងតុល្យភាពដ៏មានសារៈសំខាន់មួយ គឺអាចជាមូលហេតុនៃការខ្ជះខ្ជាយ ការកំណត់អាទិភាពខុស និងជួនកាលការកើតមានអំពើពុករលួយ។

## តើប្រទេសកម្ពុជាមានស្ថានភាពយ៉ាងដូចម្តេចធៀបនៅនឹងប្រទេសជិតខាងរបស់ខ្លួន?




ពិន្ទុ OBI ឆ្នាំ២០១០ នៃប្រទេសកម្ពុជា គឺ ១៥ លើ ១០០ ដែលប្រហែលត្រូវជាមួយភាគបីនៃពិន្ទុមធ្យម (៤២) សម្រាប់ប្រទេសដែលបានធ្វើអង្កេតទាំង៩៤។ ពិន្ទុរបស់ប្រទេសកម្ពុជា គឺស្ថិតក្នុងចំណោមពិន្ទុទាបជាងគេបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលខ្ពស់ជាងតែពិន្ទុ ១៤ របស់ប្រទេសវៀតណាមប៉ុណ្ណោះ ហើយដែលពិន្ទុទាំងពីរនេះគឺក្រោម ៣៦ ដែលជាពិន្ទុ OBI មធ្យមប្រចាំតំបន់ ។ ប្រការនេះធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាស្ទើរតែមិនអាចទាមទារឱ្យរាជរដ្ឋាភិបាល មានគណនេយ្យភាពលើការគ្រប់គ្រងរបស់ខ្លួនលើធនធានសាធារណៈ។

មានប្រទេសចំនួនបីនៅក្នុងអាស៊ាន (ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងហ្វីលីពីន) ដែលមានចំនួនឯកសារដែលបានផ្សព្វផ្សាយច្រើនជាងកម្ពុជា ខណៈដែលប្រទេសថៃ និងវៀតណាមផ្សព្វផ្សាយចំនួនឯកសារថវិកាស្ទើគ្នានឹងប្រទេសកម្ពុជាដែរ។ សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល គឺជាឯកសារថវិកា ដែលជាទូទៅត្រូវបានផ្សព្វផ្សាយដោយប្រទេសទាំងអស់នៅក្នុងតំបន់ លើកលែងតែប្រទេសកម្ពុជា និង

វៀតណាម។ ប្រទេសថៃ និងទីម័រខាងកើត បានផលិតឯកសារថវិការៀងៗគ្នាចំនួនស្មើគ្នា និងតិចជាងប្រទេសកម្ពុជា ប៉ុន្តែបានទទួលពិន្ទុ OBI ខ្ពស់ជាងកម្ពុជា។ នេះគឺព្រោះតែសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល មានសំណួរចំនួន ៥៨ នៃសំណួរចំនួន ៩២ ដែលត្រូវបានប្រើ សម្រាប់គណនាពិន្ទុ OBI ដោយសារតែសារៈសំខាន់របស់ឯកសារនេះក្នុងការផ្តល់ព័ត៌មានជូនសាធារណជនអំពីផែនការប្រមូលចំណូល និងចំណាយរបស់ស្ថាប័ននីតិប្រតិបត្តិ។ ប្រទេសកម្ពុជាអាចធ្វើឱ្យមានភាពប្រសើរឡើងថែមទៀតនូវស្ថានភាពតម្លាភាពថវិការបស់ខ្លួន ដោយផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល និងអាចលើកកម្ពស់ចំណាត់ថ្នាក់តម្លាភាពថវិការបស់ខ្លួន ដោយផ្សព្វផ្សាយឯកសារ នេះឱ្យបានទាន់ពេលវេលា និងបញ្ចូលព័ត៌មានដែលមានភាពគ្រប់ជ្រុងជ្រោយ។

**តារាង៣៖ លទ្ធភាពរកបានឯកសារថវិកាតាមប្រទេសនានានៅអាស៊ីអាគ្នេយ៍ ឆ្នាំ២០១០**

| | របាយការណ៍បុរេថវិកា | សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល | ថវិកាដែលបានអនុម័ត | ថវិកាសម្រាប់ប្រជាពលរដ្ឋ | របាយការណ៍ក្នុងឆ្នាំ | របាយការណ៍ពាក់កណ្តាលឆ្នាំ | របាយការណ៍ដំណាច់ឆ្នាំ | របាយការណ៍សវនកម្ម |
|---|---|---|---|---|---|---|---|---|
| **កម្ពុជា** | ✓ | IU | ✓ | NP | ✓ | IU | ✓ | IU |
| **ឥណ្ឌូនេស៊ី** | ✓ | ✓ | ✓ | NP | IU | ✓ | IU | ✓ |
| **ម៉ាឡេស៊ី** | NP | ✓ | ✓ | NP | ✓ | NP | ✓ | ✓ |
| **ហ្វីលីពីន** | IU | ✓ | ✓ | NP | ✓ | IU | ✓ | ✓ |
| **ថៃឡង់ដ៍** | NP | ✓ | ✓ | NP | ✓ | NP | NP | ✓ |
| **ទីម័រខាងកើត** | IU | ✓ | IU | NP | ✓ | NP | ✓ | NP |
| **វៀតណាម** | IU | IU | ✓ | NP | ✓ | NP | ✓ | ✓ |

**កំណត់សម្គាល់៖** IU៖ ឯកសារដែលបានរៀបចំសម្រាប់តែប្រើប្រាស់ផ្ទៃក្នុងប៉ុណ្ណោះ. NP៖ ឯកសារមិនបានរៀបចំ. ✓៖ ឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈ

## អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១០៖ របកគំហើញសំខាន់ៗនៃអង្កេតពិភពលោក និងសារសម្រាប់កម្ពុជា

សាធារណជននៅក្នុងប្រទេសភាគច្រើននៃប្រទេសទាំង ៩៤ ដែលបានវាយតម្លៃនៅក្នុងការអង្កេតនេះ មានលទ្ធភាពមានកម្រិតក្នុងការទទួលបានសូម្បីតែព័ត៌មានមូលដ្ឋានអំពីចំណូល និងចំណាយរបស់រដ្ឋាភិបាលរបស់ខ្លួន។ ហេតុដូច្នេះ ពួកគេមានលទ្ធភាពតិចតួចក្នុងការយល់ដឹង ឬធ្វើឱ្យមានឥទ្ធិពលលើអាទិភាពថវិការបស់រដ្ឋាភិបាលរបស់ខ្លួន។

ទោះជាយ៉ាងណាក្តី និន្នាការទូទៅឆ្ពោះទៅកាន់ការផ្សព្វផ្សាយព័ត៌មានថវិកាគឺមានលក្ខណៈអំណោយផល។ តម្លាភាពថវិកាកំពុងតែមានភាពល្អប្រសើរឡើងយ៉ាងច្រើន ជាពិសេសនៅក្នុងចំណោមបណ្តាប្រទេសដែលផ្តល់ព័ត៌មានតិចតួចកាលពីឆ្នាំកន្លងទៅ។ រដ្ឋាភិបាលខ្លះ ជាពិសេសរដ្ឋាភិបាលទាំងឡាយដែលទទួលបានពិន្ទុទាបខ្លាំងនៅក្នុងអង្កេត OBS លើកមុនៗ ភាគច្រើនសម្រេចបានពិន្ទុ OBI ខ្ពស់ជាងមុន ដោយសារបានចាប់យកនូវជំហានជាមូលដ្ឋាន និងដែលចំណាយតិចតួចមួយគឺ៖ ពួកគេបានចាប់ផ្តើមផ្សព្វផ្សាយនៅគេហទំព័ររបស់ខ្លួននូវឯកសារថវិកាដែលពួកគេបានផលិត ដែលកាលពីមុនត្រូវបានផ្តល់ឱ្យសម្រាប់តែស្ថាប័នផ្ទៃក្នុងរដ្ឋាភិបាល ឬម្ចាស់ជំនួយប៉ុណ្ណោះ។ ***ក្នុងករណីជាច្រើន រដ្ឋាភិបាលទាំងនេះបានចាប់ផ្តើមផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់ខ្លួន ដែលអាចនិយាយបានថាជា ឯកសារគោលនយោបាយក្នុងស្រុកដ៏សំខាន់បំផុតដែលរដ្ឋាភិបាលណាក៏ផលិតដែរ។*** ឧទាហរណ៍ រដ្ឋាភិបាលប្រទេសលីបេរីយ៉ា និងយេម៉ែន បានផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់ខ្លួនលើកទីមួយក្នុងឆ្នាំ២០០៩។ ឧទាហរណ៍ទាំងនេះ ផ្តល់ក្តីសង្ឃឹមដែលថារដ្ឋាភិបាលនៃប្រទេសទាំង ២២ ដែលបានរាប់បញ្ចូលក្នុងអង្កេតឆ្នាំ ២០១០ អាចផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់ខ្លួន ដើម្បីកែលម្អបានយ៉ាងលឿននូវកម្រិតនៃតម្លាភាពថវិការបស់ខ្លួន។

តារាង៤ បង្ហាញថាថវិកាដែលបានអនុម័តគឺជាឯកសារដែលត្រូវបានផ្សព្វផ្សាយជាទូទៅច្រើនជាងគេៈ មានតែ ១៣ ភាគរយប៉ុណ្ណោះនៃប្រទេសដែលបានធ្វើអង្កេតដែលមិនបានផ្សព្វផ្សាយឯកសារនេះ។ ***ប្រទេសចំនួនប្រហែលមួយ ក្នុងចំណោមប្រទេសចំនួនបួនមិនបានផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល របាយការណ៍ក្នុងឆ្នាំ ឬរបាយការណ៍ដំណាច់ឆ្នាំ។***

**តារាង ៤: ភាគរយនៃបណ្តាប្រទេសដែលមិនបានផ្សព្វផ្សាយឯកសារថវិកា**

| ឯកសារ | ភាគរយនៃប្រទេសដែលមិនបានផ្សព្វផ្សាយ |
|---|---|
| របាយការណ៍បុរេថវិកា | ៦៥% |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល | ២៣% |
| ថវិកាសម្រាប់ប្រជាពលរដ្ឋ | ៨៣% |
| ថវិកាដែលបានអនុម័ត | ១៣% |
| របាយការណ៍ក្នុងឆ្នាំ | ២៥% |
| របាយការណ៍ពាក់កណ្តាលឆ្នាំ | ៧០% |
| របាយការណ៍ដំណាច់ឆ្នាំ | ២២% |
| របាយការណ៍សវនកម្ម | ៣៥% |

អង្កេតនេះរកឃើញថាការចូលរួមជាសាធារណៈក្នុងដំណើរការថវិកា និងការត្រួតពិនិត្យដោយស្ថាប័នសវនកម្ម និងស្ថាប័ននីតិបញ្ញត្តិនៅកម្រិតពិភពលោកជាទូទៅ គឺមានលក្ខណៈទន់ខ្សោយ និងជាប់ទាក់ទងខ្លាំងជាមួយនឹងកង្វះព័ត៌មានថវិកាដែលផ្តល់ជូនដល់ស្ថាប័នទាំងនេះ និងសាធារណជន។ ស្ថាប័ននីតិបញ្ញត្តិនៅក្នុងប្រទេសមួយចំនួន មិនមានអំណាចគ្រប់គ្រាន់ដើម្បីធ្វើវិសោធនកម្មថវិកា ដែលបានរៀបចំដោយស្ថាប័ននីតិប្រតិបត្តិទេ និងមិនត្រូវបានផ្តល់ជូននូវពេលវេលាគ្រប់គ្រាន់ឡើយដើម្បីវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយលើសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល មុននឹងអនុម័តឯកសារនេះឱ្យក្លាយទៅជាច្បាប់។ មានតែនៅក្នុងប្រទេសចំនួន ២៧ ប៉ុណ្ណោះ ដែលស្ថាប័ននីតិប្បញ្ញត្តិមានអំណាចទាំងស្រុងក្នុងការធ្វើវិសោធនកម្មថវិកា ដែលបានដាក់ជូនស្ថាប័នទាំងនេះ។ នៅក្នុងប្រទេសចំនួន ២២ អ្នកតាក់តែងច្បាប់ត្រូវបានផ្តល់ជូននូវសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់ រដ្ឋាភិបាលតិចជាងប្រាំមួយសប្តាហ៍មុនពេលការចាប់ផ្តើមឆ្នាំថវិកា។ ក្នុងការអនុវត្តថវិកានៅក្នុងប្រទេសចំនួន ៥២ ស្ថាប័ននីតិបញ្ញត្តិមិនមាន អំណាចរារាំងស្ថាប័ននីតិប្រតិបត្តិមិនឱ្យបង្វិលមូលនិធិរវាងអង្គភាពរដ្ឋបាលនានាឡើយ ដែលជាមូលដ្ឋានគឺមិនសូវយកចិត្តទុកដាក់លើចេតនារបស់ស្ថាប័ននីតិប្បញ្ញត្តិ។ លើសពីនេះទៀត ស្ថាប័ននីតិប្បញ្ញត្តិនៅក្នុងប្រទេសតែចំនួន ២៦ ប៉ុណ្ណោះដែលផ្តល់ជូនសាធារណជននូវឱកាសផ្លូវការដើម្បីផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលពិភាក្សាលើសេចក្តីព្រាងច្បាប់ថវិកា។ ប្រការគួរឱ្យរំខានជាងនេះទៅទៀតគឺថានៅក្នុងប្រទេសចំនួន ៣៥ រាល់ការពិភាក្សាអំពីថវិការវាងស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ រួមទាំងសវនាការនានា គឺមានលក្ខណៈបិទជិតទាំងស្រុងចំពោះសាធារណជន (រួមទាំងបណ្តាញសារព័ត៌មាន) ហើយក៏គ្មានកំណត់ត្រាជាសាធារណៈណាអំពីកិច្ចប្រជុំបែបនេះត្រូវបានផ្សព្វផ្សាយ ក្រោយពេលប្រជុំដែរ។

អង្កេតនេះក៏រកឃើញផងដែរថាស្ថាប័នសវនកម្មកំពូលជាទូទៅមានឯករាជ្យភាពខ្លះដែលតម្រូវដល់ពួកគេក្នុងការបំពេញតួនាទីដ៏មានសារៈសំខាន់មួយនៅក្នុងដំណើរការថវិកា។ ប៉ុន្តែស្ថាប័ននេះក្នុងប្រទេសជាច្រើនទៀតនៅតែខ្វះឯករាជ្យភាពទាំងស្រុងពីស្ថាប័ននីតិប្រតិបត្តិដែលគេត្រូវការ ហើយពាក់កណ្តាលនៃស្ថាប័នទាំងនេះរាយការណ៍ថា ពួកគេមិនមានធនធានគ្រប់គ្រាន់ដើម្បីបំពេញអាណត្តិសវនកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពឡើយ។ អង្កេតឆ្នាំ ២០១០ ក៏លាតត្រដាងផងដែរថាអំណាចជារួមនៃស្ថាប័នសវនកម្មកំពូលគឺមានលក្ខណៈខ្សោយ។ នៅក្នុងចំណោមប្រទេសទាំង ៩៤ នៅក្នុងអង្កេតឆ្នាំ ២០១០ ពិន្ទុមធ្យមសម្រាប់សំណួរដែលវាយតម្លៃលើអំណាចរបស់ស្ថាប័នសវនកម្មកំពូលគឺបានត្រឹមតែ ៤៩ ប៉ុណ្ណោះនៃពិន្ទុសរុប១០០ ដែលឡើងខ្ពស់បន្តិចពីឆ្នាំ ២០០៨។ ដើម្បីធ្វើការត្រួតពិនិត្យថវិកាប្រកបដោយប្រសិទ្ធភាព ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូលតម្រូវឱ្យមានសមត្ថកិច្ចផ្លូវច្បាប់ ឬកាន់តែវិសេសទៀតសមត្ថកិច្ចកំណត់ដោយរដ្ឋធម្មនុញ្ញដែលកំណត់ពីមុខងារ និងទំនាក់ទំនងរបស់ពួកគេជាមួយនឹងស្ថាប័ននីតិប្រតិបត្តិ។ ស្ថាប័នសវនកម្មកំពូល ជាទូទៅទទួលបានពិន្ទុសម្រាប់សំណួរដែលវាយតម្លៃលើភាពគ្រប់ជ្រុងជ្រោយនៃរបាយការណ៍សវនកម្មដែលបានផ្សព្វផ្សាយ ទាបជាងពិន្ទុសម្រាប់សំណួរដែលវាយតម្លៃលើឯករាជ្យភាពរបស់

ពួកគេច្រើន។ ប្រការនេះបង្ហាញថាបើ ទោះជាអំណាចស្ថាប័នរបស់ពួកគេនៅមានកម្រិតក្តីក៏ពួកគេអាចផ្សព្វផ្សាយព័ត៌មានជាច្រើនបន្ថែមទៀតនៅក្នុងរបាយការណ៍សវនកម្មរបស់ខ្លួន។ ការដែលសំខាន់គឺ ***ស្ថាប័ននីតិប្បញ្ញត្តិនិងស្ថាប័នសវនកម្មកំពូលអាចមានប្រសិទ្ធភាពបំផុតនៅពេលដែលពួកគេមានទាំងអំណាចផ្លូវច្បាប់ផង សមត្ថភាពស្រាវជ្រាវផង និងព័ត៌មានដ៏គ្រប់ជ្រុងជ្រោយស្តីពីហិរញ្ញវត្ថុ សាធារណៈផង។***

## ប្រទេសដែលផ្សព្វផ្សាយព័ត៌មានថវិកាតិចបំផុត និងច្រើនជាងគេបំផុតៈ ប្រទេសកំពុងអភិវឌ្ឍន៍ក៏អាចកែលម្អតម្លាភាពថវិការបស់ខ្លួនបានដែរដោយចំណាយតិចបំផុត

យោងតាមសន្ទស្សន៍ OBI ឆ្នាំ ២០១០ ប្រទេសដែលអន់ជាងគេ ពោលគឺប្រទេសដែលផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ដល់សាធារណជនរួមមាន អារ៉ាប៊ីសាអូឌីត អាល់ហ្សេរី ឆាដ អ៊ីរ៉ាក់ ហ្គីណេអេក្វាទ័រ ហ្វីជី និង សាវតូម៉េ អេប្រាំងស៊ីប៉េ។ ប្រទេសដែលមានតម្លាភាពបំផុតដែលផ្តល់ព័ត៌មានថវិកាបរិបូណ៌ជូនសាធារណជននៅក្នុងដំណើរការថវិកាទាំងមូលរួមមាន អាហ្វ្រិកខាងត្បូង ណូវែលហ្សេឡង់ ចក្រភពអង់គ្លេស បារាំង ណ័រវ៉េ ស៊ុយអែដ និងសហរដ្ឋអាមេរិក។

មានការកត់សម្គាល់ផងដែរថា ប្រទេសដែលផ្តល់ព័ត៌មានច្រើន និងពេញលេញស្តីពីថវិការួមមានទាំងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ ប្រទេសទាំងឡាយដែលផ្តល់ព័ត៌មានច្រើនជាងគេបំផុត គឺប្រទេសអភិវឌ្ឍន៍លោកខាងលិច ប៉ុន្តែប្រទេសទាំងនេះក៏រួមមានផងដែរនូវប្រទេសអាហ្វ្រិកខាងត្បូងដែលទទួលពិន្ទុ OBI ឆ្នាំ២០១០ ខ្ពស់បំផុតជារួម។ ហើយគួរឱ្យកត់សម្គាល់ផងដែរ គឺថាប្រទេសមានប្រាក់ចំណូលទាបមួយចំនួន ដូចជាប្រទេសឥណ្ឌា ស្រីលង្កា និងអ៊ុយក្រែន ផ្តល់ព័ត៌មានថវិកាយ៉ាងច្រើន។ ប្រការនេះបង្ហាញថា ប្រទេសកំពុងអភិវឌ្ឍន៍អាចសម្រេចបានតម្លាភាព ប្រសិនបើមានឆន្ទៈគ្រប់គ្រាន់របស់រដ្ឋាភិបាលក្នុងការបើកចំហ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋខ្លួន។

## វិធីសាស្ត្រៈ អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាដោយផ្អែកលើកម្រងសំណួរពេញលេញ

អង្កេត OBS មិនមែនជាការស្ទង់មតិ ឬជាទស្សនៈទេ។ អង្កេតនេះវាយតម្លៃតម្លាភាពថវិកានៅកម្រិតរដ្ឋាភិបាលថ្នាក់ជាតិ ឬថ្នាក់សហព័ន្ធ ដោយវាយតម្លៃលើភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានស្តីពីចំណូល ចំណាយ និងបំណុលរបស់រដ្ឋាភិបាល ក៏ដូចជាទិន្នន័យទាក់ទិននឹងស្ថានភាពនៃការអនុវត្តតាមគោលដៅថវិកា និងការសម្រេចបានជាក់ស្តែងនូវគោលដៅទាំងនេះ។ ទិន្នន័យនៃអង្កេតត្រូវបានប្រមូលបញ្ចូលគ្នាពីកម្រងសំណួរមួយ ដែលត្រូវបានបំពេញសម្រាប់ប្រទេសនីមួយៗដោយអ្នកស្រាវជ្រាវ ឬក្រុមអ្នកស្រាវជ្រាវឯករាជ្យដែលមិនធ្វើការចំណុះឱ្យរដ្ឋាភិបាល។ សម្រាប់អង្កេតឆ្នាំ ២០១០ អ្នកស្រាវជ្រាវបានឆ្លើយនឹងសំណួរពហុជម្រើសចំនួន ១២៣ នៃកម្រងសំណួរដែលគ្របដណ្តប់លើដំណាក់កាលទាំងបួននៃដំណើរការ ឬវដ្តថវិកា ពោលគឺការរៀបចំ ការអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ ការអនុវត្ត និងសវនកម្ម ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃតម្លាភាពថវិកានៅក្នុងប្រទេសរបស់ពួកគេ គិតមកត្រឹមថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩។ ហេតុដូច្នេះ របាយការណ៍ និងឯកសារថវិកាជាតិ ក៏ដូចជាការអភិវឌ្ឍអ្វីផ្សេងទៀតនៅក្នុងប្រព័ន្ធថវិកា ឬការអនុវត្តថវិកាទាំងឡាយណារបស់ប្រទេសដែលកើតឡើងក្រោយកាលបរិច្ឆេទនេះមិនត្រូវបានដាក់បញ្ចូលទៅក្នុងអង្កេត OBS ឆ្នាំ២០១០ ឡើយ។ ដើម្បីចាត់ទុកថាអាចរកបានជាសាធារណៈនៅក្នុងអង្កេតនេះ ឯកសារថវិកាត្រូវតែបំពេញលក្ខណៈវិនិច្ឆ័យជាមូលដ្ឋានពីរគឺ (១) ឯកសារត្រូវតែត្រូវបានផ្សព្វផ្សាយនៅក្នុងពេលវេលាសមស្របមួយដោយស្ថាប័ន ឬភ្នាក់ងារទទួលបន្ទុកលើការកសាងឯកសារនេះ និង (២) ឯកសារត្រូវតែអាចរកបានក្នុងតម្លៃទាបសម្រាប់ជនណាដែលចង់បានឯកសារនេះ (ពោលគឺរដ្ឋាភិបាលមិនត្រូវផ្សព្វផ្សាយឯកសារតាមជម្រើសរបស់ខ្លួន ឬផ្សព្វផ្សាយជូនតែបុគ្គល ឬក្រុមមួយចំនួនណាឡើយ)។

កម្រងសំណួរដែលបានឆ្លើយរួចសម្រាប់ប្រទេសនីមួយៗត្រូវបានពិនិត្យមើលឡើងវិញដោយឯករាជ្យដោយអ្នកជំនាញអនាមិកពីររូបដែលមិនធ្វើការចំណុះឱ្យរដ្ឋាភិបាលទេ។ បន្ថែមលើនេះទៀត IBP បានស្នើសុំរដ្ឋាភិបាលនៃប្រទេសទាំង ៨៨ (រួមទាំងប្រទេសកម្ពុជា) ដែលរាប់បញ្ចូល ក្នុងអង្កេតឆ្នាំ២០១០ ឱ្យផ្តល់មតិយោបល់លើកម្រងសំណួរដែលត្រូវបានបំពេញសម្រាប់ប្រទេសនោះ។ ប្រហែលពាក់កណ្តាល

នៃរដ្ឋាភិបាលទាំងនេះបានផ្តល់យោបល់លើលទ្ធផលរបស់ខ្លួន។ យោបល់របស់ពួកគេត្រូវបានដាក់នៅក្នុងឯកសារនៃកម្រងសំណួរអង្កេតប្រចាំប្រទេស ដែលត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ IBP ។ បុគ្គលិក IBP ពិនិត្យមើលឡើងវិញនូវលទ្ធផលសម្រាប់ប្រទេសនីមួយៗដោយផ្ទួតពិនិត្យមើលសេចក្តីដកស្រង់ និងយោបល់ដែលបានផ្តល់ដោយអ្នកស្រាវជ្រាវ ដើម្បីធ្វើយុត្តិកម្មពិន្ទុសម្រាប់សំណួរនីមួយៗ។ លើសពីនេះទៀត បុគ្គលិក IBP បានវាយតម្លៃយោបល់របស់អ្នកជួយពិនិត្យមើល និងយោបល់ពីរដ្ឋាភិបាល (នៅពេលដែលត្រូវបានផ្តល់តាមពេលវេលាដែលបានកំណត់) និងបានកំណត់សម្រេចចម្លើយចុងក្រោយ ដោយមានការពិគ្រោះយោបល់ជាមួយអ្នកស្រាវជ្រាវ។ ការកំណត់សម្រេចទាំងនេះត្រូវបានធ្វើឡើងបន្ទាប់ពីការពិចារណាកត្តានានាដូចជា ភាពអាចប្រៀបធៀបគ្នាបាននៃទិន្នន័យរវាងប្រទេស និងសង្គតិភាពនៃការសន្មត់ដែលត្រូវបានប្រើដោយអ្នកស្រាវជ្រាវដើម្បីឆ្លើយសំណួរទាំងនេះ។

សន្ទស្សន៍ OBI គឺផ្អែកលើការគណនាមធ្យមភាគនៃចម្លើយលើសំណួរទាំង ៩២ ដែលសួរអំពីលទ្ធភាពរកបានជាសាធារណៈ ភាពទាន់ពេលវេលា និងភាពគ្រប់ជ្រុងជ្រោយនៃរបាយការណ៍ថវិការបស់ប្រទេស។ សំណួរនៃអង្កេតដែលនៅសេសសល់ វាយតម្លៃលើអំណាច និងប្រសិទ្ធភាពរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូល (ក៏ដូចជាឯករាជ្យភាពរបស់ស្ថាប័នទាំងនេះដែរ) ក្នុងប្រទេសនីមួយៗដែលបានសិក្សា។ សំណួរនីមួយៗនៃសំណួរទាំង ៩២ ដែលត្រូវបានប្រើដើម្បីបង្កើតសន្ទស្សន៍ OBI ត្រូវបានផ្តល់ទម្ងន់ស្មើគ្នាសម្រាប់ប្រទេសមួយ។ ពិន្ទុដែលបានដាក់ឱ្យសំណួរទាំង ៩២ នេះត្រូវបានប្រើដើម្បីកំណត់កម្រិតតម្លាភាពជារួមមួយ។ បន្ទាប់មក ពិន្ទុទាំងនេះត្រូវបានប្រមូលចូលគ្នាដើម្បីបង្កើតជាសន្ទស្សន៍ OBI ដែលជាចំណាត់ថ្នាក់មិនលំអៀងមួយនៃកម្រិតតម្លាភាពថវិកាប្រៀបធៀបរបស់ប្រទេសនីមួយៗ។

ទោះជាយ៉ាងណាក៏ដោយ ក៏សំណួរសម្រាប់ឯកសារថវិកាទាំងប្រាំបីដែលបានវាយតម្លៃនីមួយៗគឺមានចំនួនខុសគ្នា។ ប្រសិនបើឯកសារមួយមិនអាចរកបានជាសាធារណៈទេ នោះសំណួរទាំងអស់ដែលទាក់ទិននឹងឯកសារនេះត្រូវបានផ្តល់ពិន្ទុសូន្យជាស្វ័យប្រវត្តិ។ ជាលទ្ធផលនៃប្រព័ន្ធផ្តល់ពិន្ទុនេះ ឯកសារថវិកាខ្លះមានទម្ងន់ជាងឯកសារថវិកាខ្លះទៀត។ ឧទាហរណ៍ សំណួរចំនួន ៥៨ នៃសំណួរទាំង ៩២ ដែលត្រូវបានប្រើដើម្បីបង្កើតពិន្ទុ OBI គឺទាក់ទងនឹងសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល ដូច្នេះហើយប្រសិនបើប្រទេសមួយមិនមានផ្សព្វផ្សាយឯកសារនេះទេ ប្រទេសនោះទទួលបានពិន្ទុសូន្យសម្រាប់គ្រប់សំណួរទាំង ៥៨ ហើយពិន្ទុ OBI របស់ប្រទេសនោះទំនងជាមានលក្ខណៈទាបខ្លាំង។ ការសង្កត់ធ្ងន់លើសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល គឺដោយសារតែឯកសារនេះជាឯកសារគោលនយោបាយសេដ្ឋកិច្ចដ៏សំខាន់បំផុតរបស់រដ្ឋាភិបាល។ សម្រាប់ឯកសារនីមួយៗនៃឯកសារដែលនៅសល់ គឺមានសំណួរចំនួនចន្លោះពីមួយទៅដប់។

ការវិភាគរបស់ IBP លើសន្ទស្សន៍ OBI ចាត់ថ្នាក់ប្រទេសមួយទៅក្នុងក្រុមមួយក្នុងចំណោមក្រុមទាំងប្រាំ ដោយផ្អែកទៅលើពិន្ទុ OBI ជារួមរបស់ប្រទេសនោះ (១) ប្រទេសទាំងឡាយណាដែលទទួលពិន្ទុចន្លោះពី ៨១ ដល់ ១០០ ត្រូវបានចាត់ថ្នាក់ថា **ផ្តល់ព័ត៌មានបរិបូណ៌** (២) ប្រទេសទាំងឡាយដែលទទួលបានពិន្ទុចន្លោះពី ៦១ ដល់ ៨០ ត្រូវបានចាត់ថ្នាក់ថា **ផ្តល់ព័ត៌មានច្រើន** (៣) ប្រទេសទាំងឡាយដែលទទួលបានពិន្ទុចន្លោះពី ៤១ ដល់ ៦០ ត្រូវបានចាត់ថ្នាក់ថា **ផ្តល់ព័ត៌មានខ្លះ** (៤) ប្រទេសទាំងឡាយដែលទទួល បានពិន្ទុចន្លោះពី២១ ដល់ ៤០ ត្រូវបានចាត់ថ្នាក់ថា **ផ្តល់ព័ត៌មានតិចតួច** ហើយ (៥) ប្រទេសទាំងឡាយដែលទទួលបានពិន្ទុចន្លោះពី ០ ដល់ ២០ ត្រូវបានចាត់ថ្នាក់ថា **ផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ឬមិនផ្តល់ព័ត៌មាន** ស្តីពីថវិការបស់ខ្លួន។

# ចំណាត់ថ្នាក់តម្លាភាពថវិកាអន្តរជាតិសម្រាប់ឆ្នាំ ២០១០




* ពិន្ទុទាំងអស់នៅក្នុងសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១០នេះ ត្រូវបានកំណត់យកត្រឹមលេខគត់ ដែលក្នុងនោះករណីដែលប្រទេសដែលបានពិន្ទុលើសសូន្យបន្តិច គឺត្រូវកំណត់យកពិន្ទុសូន្យដោយហេតុថាពិន្ទុនោះមិនអាចឆ្លុះបញ្ចាំងថាប្រទេសទាំងនោះបានផ្សព្វផ្សាយព័ត៌មានថវិកាមួយចំនួនបានទេ។ ប្រទេសទាំងនោះរួមមានប្រទេសឆាត និងអ៊ីរ៉ាក់ ដែលទទួលបានពិន្ទុត្រឹមតែ 0.៤។

## អនុសាសន៍សម្រាប់ប្រទេសកម្ពុជា

ដោយមានការចំណាយតិចតួច ឬមិនមាន និងដោយមានការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍នានា ដើម្បីធានាឱ្យបាននូវជោគជ័យសម្រាប់ផ្នែកតម្លាភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទីពីររាជរដ្ឋាភិបាលកម្ពុជាគប្បីអនុវត្តសកម្មភាពខាងក្រោម៖

- ផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល[៨] របាយការណ៍ពាក់កណ្តាលឆ្នាំស្តីពីការអនុវត្តថវិកា និងរបាយការណ៍សវនកម្ម (ដែលផលិតដោយអាជ្ញាធរសវនកម្មជាតិ) ឱ្យបានទាន់ពេលវេលា។
- ផ្សព្វផ្សាយគ្រប់ច្បាប់ថវិកាដែលបានអនុម័តរួច និងច្បាប់ទូទាត់ថវិកានៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[៩]
- ផលិត និងផ្សព្វផ្សាយឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋ ព្រមទាំងឯកសារណែនាំពាក់ព័ន្ធដទៃទៀតសម្រាប់ពន្យល់ពីទិដ្ឋភាពបច្ចេកទេសនៃដំណើរការ និងពាក្យពេចន៍ថវិកា។
- ផ្តល់ដល់សាធារណជននូវឱកាសក្នុងការផ្តល់សក្ខីកម្មនៅក្នុងសវនាការ ឬការពិភាក្សារបស់ស្ថាប័ននីតិបញ្ញត្តិស្តីពីថវិកា រួមទាំងការពិភាក្សាទាំងប៉ុន្មានជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅគណៈកម្មការទីពីរនៃរដ្ឋសភាផងដែរ។ ប្រការនេះអាចទៅសម្រេចបានប្រសិនបើគណៈកម្មការទីពីររៀបចំធ្វើសវនាការសាធារណៈនេះ មុនពេលការពិភាក្សានៃសម័យប្រជុំសភាពេញអង្គលើសេចក្តីព្រាងច្បាប់ស្តីពីថវិកា និងអញ្ជើញឱ្យមានការចូលរួមពីសំណាក់សាធារណជន អង្គការសង្គមស៊ីវិល គ្រឹះស្ថានសិក្សា ស្ថាប័នស្រាវជ្រាវ បណ្តាញសារព័ត៌មាន និងក្រុមផ្សេងទៀតដែលមានការចាប់អារម្មណ៍ និង
- បង្កលក្ខណៈឱ្យស្ថាប័ននីតិប្បញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ អាចមានលទ្ធភាពធ្វើការត្រួតពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយលើដំណើរការថវិកា តាមរយៈការផ្តល់នូវព័ត៌មានថវិកាដ៏គ្រប់ជ្រុងជ្រោយនៅក្នុងឯកសារថវិកាទាំងឡាយដែលដាក់ជូន និងរាយការណ៍ទៅរដ្ឋសភា និងការតម្លើងនូវថវិកាសម្រាប់អាជ្ញាធរសវនកម្មជាតិយ៉ាងហោចណាស់ស្មើនឹងកម្រិតមួយដែលអាចប្រៀបធៀបបានជាមួយនឹងអង្គភាពប្រឆាំងអំពើពុករលួយ។

## ហេតុអ្វីបានជារាជរដ្ឋាភិបាលកម្ពុជាគប្បីផ្សព្វផ្សាយឯកសារថវិកាទាំងនេះ?

ជម្រើសរបស់រាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយឯកសារថវិកាទាំងនេះឱ្យបានទាន់ពេលវេលា ផ្តល់នូវសារមួយដ៏មានទម្ងន់ទៅកាន់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតរបស់ខ្លួន។ ការផ្សព្វផ្សាយនូវព័ត៌មានថវិកាខាងលើ នឹងផ្តល់ផលជាវិជ្ជមានជាជាងផលលំបាកនៅក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់រាជរដ្ឋាភិបាល ក៏ដូចជាសម្រាប់ប្រទេសកម្ពុជាទាំងមូលដែរ។ ទង្វើនេះបង្កឱ្យមានការចូលរួមជាសាធារណៈច្រើនបន្ថែមទៀតនៅក្នុងកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយដែលរាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់ ពីព្រោះប្រសិនបើមិនមានព័ត៌មានថវិកាទេ សាធារណជននឹងមិនមានអារម្មណ៍កក់ក្តៅ និងត្រូវបានធានាឡើយ ដោយប្រឈមទៅនឹងមាត្រាមួយនៅក្នុង

---

[៨] ក្នុងអំឡុងពេលបោះពុម្ពលើកទីមួយនៃព្រឹត្តិបត្រ OBI ឆ្នាំ២០១០នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ ជូនដល់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា នៅថ្ងៃទី១២ ខែវិច្ឆិកាឆ្នាំ២០១០ គឺមួយថ្ងៃបន្ទាប់ពីការធ្វើសិក្ខាសាលាស្តីពីលទ្ធផលនៃអង្កេត OBI ឆ្នាំ២០១០ សម្រាប់ប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍រួច។ ការឆ្លើយតបជាវិជ្ជមាននេះធ្វើឡើងបន្ទាប់ពីមានសំណើសុំសេចក្តីព្រាងច្បាប់របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា នៅមុនពេលធ្វើសិក្ខាសាលាសម្រាប់ធ្វើការវិភាគថវិកា និងជូនដំណឹងដល់សមាជិកសភា។ ប៉ុន្តែក្នុងឆ្នាំ២០១១ សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ២០១២ មិនត្រូវបានផ្សព្វផ្សាយទេ ទោះបីជាមានការស្នើសុំពីសំណាក់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ជាច្រើនលើកក្តី។

[៩] គិតត្រឹមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ នៅលើគេហទំព័រគឺមានតែច្បាប់ទូទាត់ថវិកាឆ្នាំ២០០៨ និង២០០៩ ប៉ុណ្ណោះ ហើយច្បាប់ថវិកាដែលបានអនុម័តរួចទាំងអស់មិនត្រូវបានរក្សានៅលើគេហទំព័រតែមួយសម្រួលដល់ការរកបានជាសាធារណៈឡើយ។

ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ[១០] ។ អំណះអំណាងដែលមានទម្ងន់មួយដែលសំអាងដោយប្រការនេះគឺថា ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអាចមិនហ៊ានប្តឹងចោទដោយផ្ទាល់ពីបទសង្ស័យអំពើពុករលួយដល់ស្ថាប័ន ឬបុគ្គលណាឡើយនៅពេលដែលមិនមានព័ត៌មានថវិកាដ៏គ្រប់ជ្រុងជ្រោយដែលផ្សព្វផ្សាយជាសាធារណៈ ដែលពួកគេអាចប្រើបានសម្រាប់គាំទ្រជំហររបស់ខ្លួនក្នុងការប្តឹងចោទពីបទសង្ស័យណាមួយ ។

ទង្វើខាងលើនេះក៏បង្ហាញផងដែរថា រាជរដ្ឋាភិបាលមានការប្តេជ្ញាអំពីតម្លាភាព និងគណនេយ្យភាព លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ អំណះអំណាងទាំងឡាយខាងក្រោម គាំទ្រថាហេតុអ្វីរដ្ឋាភិបាលគប្បីគួរមានការបើកចំហច្រើនបន្ថែមទៀតក្នុងការគ្រប់គ្រងថវិកា ដែលគួរតែទទួលបានការពិចារណាពីសំណាក់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ពន្ធ័ទៀត ។

ជាមួយនឹងកម្រិតតម្លាភាពសមរម្យមួយៈ

- ប្រជាពលរដ្ឋអាចដឹងបាន (ទាំងស្រុង) អំពីសមិទ្ធិផលរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចបានការងារបច្ចុប្បន្នលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអាចចូលរួមបានយ៉ាងសកម្មបន្ថែមទៀតនៅក្នុងដំណើរការថវិកាសំដៅបំពេញចន្លោះប្រហោងនៅក្នុងការត្រួតពិនិត្យ និងតុល្យភាពរវាងស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័ននីតិប្បញ្ញត្តិ ។
- ទស្សនះសាធារណៈលើឯករាជ្យភាពនៃអាជ្ញាធរសវនកម្មជាតិ ពីស្ថាប័ននីតិប្រតិបត្តិ នឹងអាចត្រូវបានកែលម្អតាមរយៈការផ្សព្វ-ផ្សាយរបាយការណ៍សវនកម្មឱ្យបានទាន់ពេលវេលា ដែលអនុញ្ញាតឱ្យរដ្ឋសភាអាចទាមទាររាជរដ្ឋាភិបាលឱ្យមានគណនេយ្យភាពលើការអនុវត្តថវិកា ។
- ប្រជាពលរដ្ឋអាចមើលឃើញថាតើប្រព័ន្ធថវិការបស់រាជរដ្ឋាភិបាលមានប្រសិទ្ធភាព និងប្រសិទ្ធផលយ៉ាងដូចម្តេច ក្នុងការរួមចំណែកដល់ការសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ ដូចដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។
- កិត្តិនាមរបស់ប្រទេសកម្ពុជា ដែលឆ្លុះបញ្ចាំងដោយចំណាត់ថ្នាក់តម្លាភាពថវិកាអន្តរជាតិថាបានប្រសើរឡើង នឹងអាចជួយដល់រាជរដ្ឋាភិបាលយ៉ាងហោចណាស់មួយផ្នែកក្នុងការទាក់ទាញការវិនិយោគដោយផ្ទាល់ពីបរទេស ក៏ដូចជាការគ្រប់គ្រងជំនួយអភិវឌ្ឍន៍ឆ្ពោះទៅកាន់ការសម្រេចបាននូវរបៀបវារៈអភិវឌ្ឍន៍ប្រទេសកម្ពុជាដែរ ។
- វាក៏អាចចូលរួមចំណែកជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ក៏ដូចជាការអនុវត្តប្រកបដោយជោគជ័យនូវច្បាប់ប្រឆាំងអំពើពុករលួយដែលត្រូវបានអនុម័ត និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្រក្នុងឆ្នាំ ២០១០ ។
- វាក៏អាចចូលរួមចំណែកផងដែរជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រមូលពន្ធ និងចំណូលក្នុងស្រុកដទៃទៀតដែលអាចជួយកាត់បន្ថយការពឹងផ្អែករបស់ប្រទេសកម្ពុជាទៅលើជំនួយបរទេស និងជួយលើកកំពស់បៀវត្សរ៍របស់មន្ត្រីស៊ីវិលសាធារណៈ ឱ្យកើនឡើងដល់កម្រិតមួយដែលអាចផ្គត់ផ្គង់ជីវភាពរស់នៅរបស់ពួកគេបាន ។ លើសពីនេះទៅទៀត វាក៏អាចជួយដល់រាជរដ្ឋាភិបាលផងដែរឱ្យមានលទ្ធភាពក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ និងគោលនយោបាយបែងចែកឡើងវិញឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពជាងមុន ដូចជាការពន្លឿននូវការអនុវត្តកម្មវិធីសំណាញ់សុវត្ថិភាពសង្គម និងគាំពារសង្គម ការផ្តល់សម្បទានដី សង្គមកិច្ច និងកម្មវិធីដទៃទៀតសម្រាប់ក្រុមជនក្រីក្រ និងងាយរងគ្រោះ ។

[១០] មាត្រា៤១ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវបានអង្គការសង្គមស៊ីវិលជាច្រើនរិះគន់ថាជាការគំរាមកំហែងមួយដល់ការលើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈនៅក្នុងយុទ្ធនាការប្រឆាំងអំពើពុករលួយ ។ មាត្រានេះចែងថា *អំពើប្តឹងបរិហារដោយភូតកុហកដល់អង្គភាពប្រឆាំងអំពើពុករលួយ ឬតុលាការនូវអង្គហេតុបទល្មើសពុករលួយ កាលបើអំពើនេះនាំឱ្យធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ទៅប្រាំឆ្នាំ និងពិន័យជាប្រាក់ពីមួយសែនរៀល ទៅប្រាំលានរៀល។*

## ភាពជាដៃគូថវិកាអន្តរជាតិ និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

ភាពជាដៃគូថវិកាអន្តរជាតិ (IBP) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៧ ដែលជាផ្នែកមួយនៃមជ្ឈមណ្ឌលស្តីពីអាទិភាពថវិកា និងគោលនយោបាយ ដែលជាអង្គការស្រាវជ្រាវមិនបម្រើឱ្យគណបក្ស និងមិនស្វែងរកប្រាក់ចំណេញមួយ មានទីស្នាក់ការនៅក្រុងវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិក ដើម្បីសហការជាមួយអង្គការសង្គមស៊ីវិលនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការវិភាគតាមដាន និងធ្វើឱ្យមានឥទ្ធិពលលើដំណើរការថវិកាស្ថាប័ន និងលទ្ធផលការងាររបស់រដ្ឋាភិបាល។ ភាពជាដៃគូនេះមានគោលបំណង ធ្វើឱ្យប្រព័ន្ធថវិកាកាន់តែមានលក្ខណៈឆ្លើយតបច្រើនឡើងទៅនឹងសេចក្តីត្រូវការរបស់ប្រជាជនក្រីក្រ និងប្រជាជនមានប្រាក់ចំណូលទាបនៅក្នុងសង្គម និងដោយហេតុនេះ សំដៅធ្វើឱ្យប្រព័ន្ធទាំងនេះកាន់តែមានតម្លាភាព និងគណនេយ្យភាពចំពោះសាធារណជន។ សម្រាប់ព័ត៌មានបន្ថែមស្តីពីភាពជាដៃគូថវិកាអន្តរជាតិ និង គំនិតផ្តួចផ្តើមការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១០ សូមមើលគេហទំព័រ: www.internationalbudget.org និង www.openbudgetindex.org ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) គឺជាអង្គការសមាជិកភាពមួយ ដែលរួមមានអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលធ្វើការនៅប្រទេសកម្ពុជា។ អង្គការនេះបង្កើតឡើងដើម្បីចែករំលែកព័ត៌មាន ពិភាក្សាដេញដោល និងតស៊ូមតិលើបញ្ហាអាទិភាពនានាដែលប៉ះពាល់ដល់ការអភិវឌ្ឍប្រទេសកម្ពុជា។ គម្រោងថវិកាជាតិរបស់អង្គការនេះ ត្រូវបានឧបត្ថម្ភគាំទ្រ មួយផ្នែកដោយភាពជាដៃគូថវិកាអន្តរជាតិ។ សម្រាប់ព័ត៌មានបន្ថែមស្តីពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមមើលគេហទំព័រ: www.ngoforum.org.kh ។

**បោះពុម្ពផ្សាយដោយ:** គម្រោងថវិកាជាតិនៃកម្មវិធីបញ្ហាអភិវឌ្ឍន៍នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
*The NGO Forum on Cambodia*
ធ្វើការរួមគ្នាដើម្បីការប្រសើរឡើង
*Working Together for Positive Change*

IBP | INTERNATIONAL BUDGET PARTNERSHIP
Open Budgets. Transform Lives.

អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន ក្រុងភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ: ២២៩៥ រាជធានីភ្នំពេញ ៣ កម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ៤២៩ ទូរសារលេខ: (៨៥៥) ២៣ ៩៩៤ ០៦៣
គេហទំព័រ: www.ngoforum.org.kh អ៊ីម៉ែល: ngoforum@ngoforum.org.kh